# ព្រះវិហារឥតជញ្ជាំងក្នុងវត្តសំបូរ

វត្តពោធិរោងសេះ ឬអ្នកស្រុកហៅថា "វត្តសំបូរ"[១] ស្ថិតក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ពោលគឺស្ថិតនៅខាងកើតរមណីយដ្ឋានប្រវត្តិសាស្ត្រក្រុមប្រាសាទសំបូរព្រៃគុក ចម្ងាយប្រហែលជាង១០គីឡូម៉ែត្រប៉ុណ្ណោះ។ សព្វថ្ងៃនៅក្នុងបរិវេណវត្តសំបូរ គេឃើញមានព្រះវិហារពីរសាងទន្ទឹមគ្នា (រូបលេខ១)។ ព្រះវិហារខាងឆ្វេង គឺជាព្រះវិហារចាស់ ដែលជាសំណង់ដ៏ល្អឆើត សាងសង់ឡើងក្នុងរវាងដើមទសវត្សទី២០ នៃចុងសម័យអាណាព្យាបាលបារាំង។ លក្ខណៈស្ថាបត្យកម្មនៃព្រះវិហារនេះ មានទម្រង់ជាព្រះវិហារជហ្វាពីរ គ្រឿងបង្គុំឈើ ពិតានឈើ និងមានសសរបេតុងជិត៥០ដើម តែគ្មានជញ្ជាំងឡើយ។ ព្រះវិហារបែបនេះ គឺជាលក្ខណៈសំណង់បុរាណមួយបែប ដែលកម្រឃើញមាននៅបណ្តាខេត្តផ្សេងៗ។ រីឯព្រះវិហារថ្មីកសាងជាប់នឹងគ្រឹះព្រះវិហារចាស់ ហើយរួចរាល់ជាស្ថាបពរ និងបានធ្វើបុណ្យបញ្ចុះសីមាឆ្លងក្នុងឆ្នាំ២០១៥។



រូបលេខ១ ព្រះវិហារវត្តសំបូរ (មើលពីមុខ)

---

[១] ការសរសេរពាក្យនេះសង្កេតឃើញតាមនិយមរៀងៗខ្លួន ខ្លះសរសេរ "សម្បូរណ៍" ឬ "សម្បូណ៌"។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# អត្ថបទ៖ ព្រះវិហារឥតជញ្ជាំងក្នុងវត្តសំបូរ

ព្រះវិហារចាស់វត្តសំបូរ កសាងឡើងនៅលើខឿនកម្ពស់ប្រហែល១ម៉ែត្រ។ បន្ទាប់ពីសាងសង់ព្រះវិហារថ្មីរួចជាស្ថាពរមក ខឿនព្រះវិហារទាំងពីរបានរៀបភ្ជាប់គ្នាធ្វើជាខឿនទី១ នៃព្រះវិហារថ្មី (រូបលេខ២-៣)។ ដោយឡែកបើនិយាយតែព្រះវិហារចាស់ គេសង្កេតឃើញថាជាព្រះវិហារដែលមានកម្ពស់ទាបល្មម ដំបូលប្រក់ក្បឿងស្រកាលេញជ្រាលចុះសងខាងពីរថ្នាក់។ នៅចុងព្រំដំបូលខាងមុខបំពាក់ជហ្វាមួយ ហើយចុងព្រំដំបូលខាងក្រោយក៏បំពាក់ជហ្វាមួយដែរ (រូបលេខ៤)។ នៅចំកណ្តាលព្រំដំបូល រចនាលម្អក្បាច់មួយផ្ទាំង[២] មានចារឹកភ្ជាប់នឹងលេខ “1941” (រូបលេខ៥) ដែលក្បាច់លម្អមួយផ្ទាំងនេះក៏ឃើញចម្លងប្រើបន្តលើព្រំដំបូលព្រះវិហារថ្មីដែរ។ រីឯនៅតាមចែងដំបូលនីមួយៗ លម្អដោយនាគចែងក្នុងមួយជ្រុងចំនួន៣ ដែលក្បាលនាគខ្លះមានការរចនាពីសសៃដែកធ្វើជាអណ្តាតនាគប្រកបដោយសិល្បៈយ៉ាងល្អវិសេស (រូបលេខ៦)។



រូបលេខ២ ព្រះវិហារវត្តសំបូរ (មើលពីក្រោយ)



រូបលេខ៣ ព្រះវិហារថ្មីវត្តសំបូរ



រូបលេខ៤ ជហ្វា



រូបលេខ៥ ការលម្អព្រំដំបូល



រូបលេខ៦ នាគចែង

[២] ការលម្អនេះអ្នកខ្លះហៅថា “នភដំបូល” (?)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ ព្រះវិហារឥតជញ្ជាំងក្នុងវត្តសំបូរ

ចំពោះហោជាងទាំងពីរនៃព្រះវិហារចាស់វត្តសំបូរ គឺរចនាជារូប និងក្បាច់លម្អនៅលើផ្ទៃស៊ីម៉ងត៍។ នៅត្រង់ផ្នែកកណ្តាលនៃហោជាងខាងមុខ គេឆ្លាក់រូបព្រះពុទ្ធគង់ក្រោមដើមពោធិធំមួយដើម ដោយមានភិក្ខុប្រាំអង្គកំពុងថ្វាយបង្គំ ព័ទ្ធជុំវិញដោយកម្រងក្បាច់ភ្ញីទេសយ៉ាងរស់រវើក។ ទិដ្ឋភាពត្រង់នេះ ទំនងសិល្បកររចង់បង្ហាញត្រង់ឈុតមួយដកស្រង់ចេញពីរឿងពុទ្ធប្រវត្តិ ត្រង់ឈុត "ព្រះអង្គប្រោសបញ្ចវគ្គីយ៍" បន្ទាប់ពីព្រះអង្គបានត្រាស់ដឹង។

ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់ គេឆ្លាក់កាយវិការព្រះពុទ្ធគង់លើបល្ល័ង្កវ័ត្ន(?) ព្រះហស្តស្តាំគងលើព្រះបាទស្តាំ ចុងម្រាមសំយ៉ុងចុះក្រោម ព្រះហស្តឆ្វេងដាក់ផ្ងារស្របលើព្រះបាទឆ្វេង (រូបលេខ២៧)។[៣] ចំណែកឯហោជាងខាងក្រោយ គេឆ្លាក់ជារូបទេពមួយអង្គកាន់គ្រឿងសាស្ត្រាក្នុងព្រះហស្តទាំងសងខាង ឈរលើដំរីក្បាលបី (រូបលេខ២៨)។ ទេពអង្គនេះ ប្រហែលគេចង់ឆ្លាក់សំដៅដល់តួអង្គព្រះឥន្ទ្រ គង់លើជំនិះជាដំរី (ឰរ៉ាវ័ណ) ដែលតែងនិយមឃើញឆ្លាក់នៅតាមផ្តែរ ឬហោជាងប្រាសាទបុរាណនានា។[៤] សូមបញ្ជាក់ថាការលាបពណ៌លើគ្រឿងលម្អស្ថាបត្យកម្មផ្នែកខាងលើដូចជា ជហ្វា ព្រំដំបូល ក្បាលនាគហោជាង ក្បាច់គល់ហោជាង និងក្បាច់រងស្បូវជាដើម គេសង្កេតឃើញហាក់ដូចជាពុំទាន់រួចរាល់ហើយស្រេចឡើយ ដ្បិតផ្នែកខ្លះគេឃើញមានពណ៌ផ្ទៃមេឃស្រាល ផ្នែកខ្លះមានពណ៌ផ្កាឈូក ហើយផ្នែកខ្លះមានពណ៌ដីលែង។



រូបលេខ២៧ ហោជាងខាងកើត



រូបលេខ២៨ ហោជាងខាងលិច

[៣] ព្រាប ចាន់ម៉ារ៉ា ២០១៥:២៤-៣០

[៤] ឈុត វ៉ាដេត ២០១៣: ៧-៨

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក ចំពោះរចនាសម្ព័ន្ធសំណង់ផ្នែកខាងក្រោម គេសង់ឡើងដោយមានសសរបេតុងរាង៨ជ្រុងចំនួន២៨ដើម ដោយចែកចេញជាល្វែងគ្រឹះនៅកណ្ដាល អមដោយរបៀង និងបាំងសាចដូចព្រះវិហារបុរាណផ្សេងៗដែរ តែពុំមានជញ្ជាំងបាំងបិទជុំវិញឡើយ។ លក្ខណៈព្រះវិហារនេះ ស្រដៀងនឹងព្រះវិហារវត្តឥន្ទកុមារដែលកសាងឡើងនៅដើមសតវត្សទី១៩ ស្ថិតនៅភាគខាងជើងនៃខេត្តកំពង់ធំនោះដែរ។ សសរខ្លះនៃព្រះវិហារនេះមានលាបពណ៌ និងគូរក្បាច់ផ្សេងៗលម្អតាំងពីគល់សសររហូតដល់ក្បាលសសរ។ ប៉ុន្តែសសរខ្លះ ពុំលាបពណ៌អ្វីឡើយ គឺរក្សាពណ៌សាច់ស៊ីម៉ងត៍ដដែល។

រីឯចន្លោះសសរបាំងសាចនៃព្រះវិហារវត្តសំបូរ នៅតាមត្រង់ទិសធំៗទាំងបួន និងទិសតូចៗជុំវិញ គេសង្កេតឃើញមានតម្កល់សន្ទឹកសីមាធ្វាក់ពីថ្មភក់។ សន្ទឹកសីមាទាំងនោះពុំបញ្ចុះភ្ជាប់ទៅនឹងគ្រឹះព្រះវិហារឡើយ ពោលគឺតម្កល់លើទ្រនាប់ថ្មមួយជុំរាងបួនជ្រុង។ ចំណែកឯនៅចុងល្វែងគ្រឹះផ្នែកខាងលិច គេសាងបល្ល័ង្ក(អាសន៍ព្រះ?) មានចន្លោះលំហខាងក្រោម តម្កល់ព្រះបដិមាព្រះជីវ័ធំ គង់ក្នុងកាយវិការផ្ចាញ់មារ សាងពីស៊ីម៉ងត៍ អមដោយព្រះពុទ្ធបដិមាតូចធំផ្សេងៗទៀត (រូបលេខ៩)។ នៅលើក្បាលសសរខ្លះគេឃើញមានចំណារឈ្មោះម្ចាស់សទ្ធាសាងសសរ និងកាលបរិច្ឆេទព.ស.២៥០៥ ឆ្នាំ១៩៦២។



*រូបលេខ៩ ផ្នែកខាងក្នុងព្រះវិហារចាស់វត្តសំបូរ និងព្រះបដិមាព្រះជីវ័តម្កល់ក្នុងព្រះវិហារ*

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*

ទន្ទឹមនឹងនេះ នៅផ្នែកខាងលើ គេក្រាលពិតានឈើត្រង់ចន្លោះល្វែងគ្រឹះ ព្រមទាំងគូរគំនូរផងៗ សាច់រឿងគំនូរទាំងនោះ ខ្លះដកស្រង់ពីរឿងពុទ្ធប្រវត្តិ ខ្លះគូរបង្ហាញអំពីព្រះអាទិត្យ ព្រះចន្ទ្រដូចព្រះវិហារដទៃដែរ។ មិនតែប៉ុណ្ណោះ នៅត្រង់ធ្នឹមលើព្រះដីរ៍គេមានចារបញ្ជាក់ចំណងជើងឈុតដែលដកស្រង់មកគូរ ព្រះនាមព្រះចៅអធិការ និងកាលបរិច្ឆេទសាងគំនូរថា "[បន្ទាប់ទី១] កាលព្រះអង្គទ្រង់នាំពួកភិក្ខុចំនួន៥០០អង្គ ហោះឧទ្យានទៅកាន់នគរកបិលពស្តុ [បន្ទាប់ទី២] ចៅអធិការ អ៊ុន នឹងគ្រូសូត្រ សួន ព្រមទាំងឧបាសកនឹងឧបាសិកាចំណុះ [បន្ទាត់ទី៣] ជើងវត្តបានកស្អាងគំនូរនេះក្នុងឆ្នាំ១៩៦១" (រូបលេខ១០)។ ចំណែកលើធ្នឹមមួយទៀត ស្ថិតនៅខាងមុខព្រះដីរ៍មានចំណារបញ្ជាក់ថា ជាងគំនូរឈ្មោះ មុន មូល មកពីឃុំស្វាយសាច់ភ្នំ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។



រូបលេខ១០-១១ ឈុតខ្លះនៃគំនូរលើពិតានព្រះវិហារចាស់វត្តសំបូរ

បើផ្អែកតាមចំណារជាប់តាមផ្ទាំងគំនូរខ្លះៗដូចរៀបរាប់ខាងលើឱ្យដឹងថា ការលម្អក្បាច់រចនាតាមសសរ ធ្នឹម និងគំនូរលើពិតាន សាងឡើងនៅរវាងឆ្នាំ១៩៦១-១៩៦២។ លើសពីនេះ បើយោងតាមការសិក្សារបស់ Danielle និង Dominique-Pierere Guéret យល់ថាព្រះវិហារចាស់វត្តសំបូរកសាងឡើងនៅក្នុងឆ្នាំ១៩៤១[៥] ការយល់ឃើញនេះ ប្រហែលយកតាមលេខ "1941" ឆ្លាក់ជាប់នឹងក្បាច់លម្អលើកណ្ដាលព្រំដំបូលព្រះវិហារដូចរៀបរាប់មកខាងលើ។ ដូច្នេះប្រសិនបើគិតមកដល់បច្ចុប្បន្ន ព្រះវិហារចាស់ក្នុងវត្តសំបូរកសាងឡើងបានជិត៩០ឆ្នាំមកហើយ។ ចំណែកឯការលាបលនគូរក្បាច់លម្អ និងគំនូរលើពិតាន គឺធ្វើឡើងក្រោយកសាងព្រះវិហារបានរយៈពេល២០ឆ្នាំ។ ប៉ុន្តែយ៉ាងណាក្ដី គេសង្កេត

[៥] Danielle & Dominique-Pierere Guéret 2017: 128

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

ឃើញពុទ្ធបរិស័ទដែលមានជំនឿដក់ជាប់នឹងមត៌កបុរាណរបស់ដូនតា នៅតែចូលទៅគោរពបូជា ថ្វាយផ្កាភ្ញី ធូបទៀន ដល់ព្រះពុទ្ធបដិមាក្នុងព្រះវិហារចាស់។ សង្ខេបសេចក្ដីមក សំណង់ព្រះវិហារចាស់វត្តសំបូរ គឺជាកស្តុតាងយ៉ាងសំខាន់នៃការកសាងព្រះវិហារបែបបុរាណ ដែលគ្មានជញ្ជាំង។ ស្ថាបត្យកម្មបែបនេះ ហាក់ដូចជាបានរៀបចំឱ្យពន្លឺ និងខ្យល់ចេញចូលក្នុងព្រះវិហារបានល្អ ដើម្បីឱ្យព្រះសង្ឃ និងពុទ្ធបរិស័ទងាយស្រួលរៀបចំកិច្ចពិធីផ្សេងៗ។

## ឯកសារយោង

ឈុត វ៉ាដេត

២០១៣, *ព្រះឥន្ទ្រក្នុងអារ្យធម៌ខ្មែរ*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

ព្រាប ចាន់ម៉ារ៉ា

២០១៥, "ផ្ចាញ់មារ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១០, ទំ. ២៤-៣០, យសោធរ, ភ្នំពេញ

សាន ផល្លា

២០០៧, *គំនូរនៅតាមវត្ត*, វៃយំ, ភ្នំពេញ

*Danielle & Dominique-Pierere Guéret*

2017, *The Khmer Pagoda,* Kam Éditions

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត